# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈរដ្ឋមន្ត្រី**

**លេខាធិការដ្ឋានមុខងារសាធារណៈ**

លេខៈ ០៨៤ មសត្រវ

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២

## រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
## គោរពជូន
## ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

**កម្មវត្ថុៈ** សំណើសុំធ្វើសមាហរណកម្មបញ្ចូលទៅក្នុងឋានន្តរស័ក្តិតាមមុខតំណែង ក្នុងក្របខ័ណ្ឌឧត្តមមន្ត្រី ជូន ឯកឧត្តមរដ្ឋលេខាធិការចំនួន ៣០រូប ។

ខ្ញុំមានកិត្តិយស សូមជម្រាបជូនឯកឧត្តមទេសរដ្ឋមន្ត្រីមេត្តាជ្រាបថា ក្នុងចំណោមសំណើសុំធ្វើសមាហរណកម្មបញ្ចូលទៅក្នុងឋានន្តរស័ក្តិតាមមុខតំណែង ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលជូនឯកឧត្តមរដ្ឋលេខាធិការចំនួន ៣០រូបនេះ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ជូនយោបល់ដូចតទៅ :

១- បើផ្អែកតាមខ្លឹមសារនៃអនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះ ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ១៩៩៩ ស្តីពីការស្ថិតនៅក្រៅក្របខ័ណ្ឌដើមចំពោះមន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ មន្ត្រីនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ និងអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០០១ ស្តីពីគោលការណ៍សមាហរណកម្មមន្ត្រីរាជការស៊ីវិលទៅក្នុងក្របខ័ណ្ឌថ្មី នោះមិនអាចធ្វើសមាហរណកម្មបញ្ចូលទៅក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលបានឡើយ ។

២- ប៉ុន្តែបើក្នុងលក្ខណៈសម្របសម្រួលនោះ យ៉ាងហោចណាស់ជ្រើសរើសតែអ្នកដែលមានអតីតភាពបម្រើការងាររដ្ឋពី ១៦ ឆ្នាំឡើងទៅ ទើបអាចបញ្ចូលទៅក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលព្រោះលក្ខន្តិកៈដោយឡែកបានកំណត់ ។

៣- ដោយឡែក ឯកឧត្តម **ឆ គឹមនឿន** អនុរដ្ឋលេខាធិការក្រសួងការពារជាតិ ពុំមានក្របខ័ណ្ឌក្នុងរដ្ឋបាលស៊ីវិល ។

៤- ចំពោះឯកឧត្តមមួយចំនួនដែលមានអតីតភាពបម្រើការងាររដ្ឋរយៈពេលខ្លីពេក គួរធ្វើសមាហរណ-កម្មស្របតាមខ្លឹមសារអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០១ ស្តីពីគោលការណ៍សមាហ-រណកម្មមន្ត្រីរាជការស៊ីវិលទៅក្នុងក្របខ័ណ្ឌថ្មី។

សូមឯកឧត្តមទេសរដ្ឋមន្ត្រីមេត្តាជ្រាប និងទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

**ពេជ្រ ប៊ុនធិន**